ប្រសិទ្ធភាពហ្វាយនែន
Prasethpheap Finance

# របាយការណ៍ប្រចាំឆ្នាំ ២០២៥




ការិយាល័យកណ្ដាល
អគារលេខ១៣២ ផ្លូវលេខ១៩៣ កែង ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
លេខទូរសព្ទ: 023 970 000
អ៊ីមែល: **info@prasethpheapfinance.com.kh**
គេហទំព័រ: **www.prasethpheapfinance.com.kh**

# ចក្ខុវិស័យ

ជាគ្រឹះស្ថានដែលមានទំនុកចិត្ត និងឈានមុខគេនៅក្នុងប្រទេសកម្ពុជា។

# បេសកកម្ម

ផ្តល់សេវាកម្មហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋ តាមទីប្រជុំជន និងជនបទ ប្រកបដោយតម្លាភាព និងក្រមសីលធម៌វិជ្ជាជីវៈ។

# តម្លៃស្នូល

ភាពស្មោះត្រង់ ការប្តេជ្ញាចិត្ត តម្លាភាព វិជ្ជាជីវៈ យុត្តិធម៌ ការទទួលខុសត្រូវ ទំនួលខុសត្រូវ ញញឹម ។



# មាតិកា

ទំព័រ


២ ចំណាប់អារម្មណ៍របស់ ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល

៤ ចំណាប់អារម្មណ៍របស់អគ្គនាយក

៦ ប្រវត្តិរបស់ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

៩ សមិទ្ធផល របស់ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

១១ ការចូលរួមបរិច្ចាក

១២ បណ្តាញសាខា

១៤ ផលិតផល និងសេវាកម្ម

១៧ ភាគទុនិក

១៧ រចនាសម្ព័ន្ធគ្រប់គ្រង

១៨ ក្រុមប្រឹក្សាភិបាល

២១ គណៈគ្រប់គ្រង

២៤ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

២៦ ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

២៩ ដំណើរកម្សាន្តប្រចាំឆ្នាំ

៣២ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម




**អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី**

ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល



# ចំណាប់អារម្មណ៍ របស់ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល

តាងនាមក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលសុី ខ្ញុំមានកិត្តិយសយ៉ាងក្រៃលែងក្នុងការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធផលការងារប្រចាំឆ្នាំ២០២៥។ ឆ្នាំ២០២៥ គឺជាឆ្នាំមួយដែលពោរពេញដោយការសាកល្បងដ៏ស្មុគស្មាញពីបរិបទសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ប៉ុន្តែក៏ជាឆ្នាំដែលកំណត់ពីភាពធន់ ភាពរឹងមាំ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់គ្រឹះស្ថានយើង ក្នុងការបម្រើអតិថិជន និងសហគមន៍។

នៅក្នុងឆ្នាំ២០២៥ សេដ្ឋកិច្ចពិភពលោកបានបន្តស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា ដោយសាររលកបោកបក់នៃសង្គ្រាមនិងជម្លោះសកល (ជាពិសេសនៅអឺរ៉ុបខាងកើត និងមជ្ឈិមបូព៌ា) ដែលបានធ្វើឱ្យខ្សែច្រវាក់ផ្គត់ផ្គង់ និងតម្លៃថាមពលមានភាពប្រែប្រួលខ្លាំង។ ទន្ទឹមនឹងនេះ បើទោះបីជា ការរាតត្បាតនៃជំងឺកូវីដ-១៩ បានថយឥទ្ធិពលហើយបានក្លាយជាជំងឺប្រចាំតំបន់យ៉ាងណាក្តី ប៉ុន្តែផលប៉ះពាល់រលកទីពីរ មកលើកម្លាំងទិញ លំនឹងអាជីវកម្មខ្នាតតូចនិងបន្ទុកបំណុលរបស់ប្រជាពលរដ្ឋនៅតែបន្សល់ទុកជាសម្ពាធសេដ្ឋកិច្ចរហូតមកដល់បច្ចុប្បន្ននេះ។

នៅក្នុងកម្រិតតំបន់ ការប្រែប្រួលនៃបរិយាកាសពាណិជ្ជកម្ម និងសន្តិសុខតាមព្រំដែន រួមទាំងភាពតានតឹងដាច់ដោយឡែកណាមួយរវាងកម្ពុជា-ថៃ បានជះឥទ្ធិពលដោយផ្ទាល់ដល់លំហូរពាណិជ្ជកម្មឆ្លងដែន ទំហំដោះដូរកសិផល និងការធ្វើចំណាកស្រុកការងារ។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យើងបានសង្កេតឃើញថា ស្ថានភាពនេះបានបង្កើតជាបញ្ហាប្រឈមដល់ចរន្តសាច់ប្រាក់របស់អាជីវករ និងកសិករនៅតាមបណ្តាខេត្តជាប់ព្រំដែន ដែលតម្រូវឱ្យគ្រឹះស្ថានដកស្រង់បទពិសោធន៍ និងបង្កើនការយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រងហានិភ័យឥណទានក្នុងតំបន់ទាំងនោះ។

ទោះជាយ៉ាងណាក៏ដោយ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពបត់បែនរបស់ធនាគារជាតិនៃកម្ពុជា សេដ្ឋកិច្ចជាតិនៅក្នុងឆ្នាំ ២០២៥ នៅតែរក្សាបាននូវនិន្នាការវិជ្ជមាន តាមរយៈការងើបឡើងវិញនៃវិស័យទេសចរណ៍ និងការនាំចេញ។

សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ២០២៥ គឺជាឆ្នាំនៃការប្រុងប្រយ័ត្នខ្ពស់ និងការស្តារឡើងវិញ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានផ្តោតលើ៖

- **ការរក្សាគុណភាពទ្រព្យសកម្ម៖** តាមរយៈការវាយតម្លៃឥណទានយ៉ាងម៉ឺងម៉ាត់ និងការរៀបចំឥណទានឡើងវិញ ដើម្បីជួយសម្រាលបន្ទុកអតិថិជនដែលរងផលប៉ះពាល់។
- **បរិវត្តកម្មឌីជីថល៖** ការពង្រឹងប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងបង្កើនភាពងាយស្រួលជូនអតិថិជន។

ជាសេចក្តីសន្និដ្ឋាន ឆ្លងកាត់ព្យុះភ្លៀងសេដ្ឋកិច្ចក្នុងឆ្នាំ២០២៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានបង្ហាញយ៉ាងច្បាស់ពីវឌ្ឍនភាព និងស្ថិរភាពដ៏រឹងមាំរបស់ខ្លួន។ យើងបានបំប្លែងរាល់បញ្ហាប្រឈម ឱ្យទៅជាឱកាសក្នុងការកែទម្រង់ផ្ទៃក្នុង និងពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យឱ្យកាន់តែប្រសើរជាងមុន។

តាងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- **ធនាគារជាតិនៃកម្ពុជា** សម្រាប់គោលការណ៍ណែនាំ និងការគាំទ្រជានិច្ចកាល។
- **អតិថិជន និងភាគទុនិកទាំងអស់** សម្រាប់ទំនុកចិត្ត និងការដើរទន្ទឹមគ្នាក្នុងកាលៈទេសៈដ៏លំបាកនេះ។
- **គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់លំដាប់ថ្នាក់** សម្រាប់ស្មារតីសាមគ្គីភាព និងការខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ ដើម្បីឧត្តមភាពនៃគ្រឹះស្ថាន។

យើងទន្ទឹងរង់ចាំឆ្នាំ២០២៦ ដោយក្តីសង្ឃឹម និងការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និរន្តរភាព និងបរិយាបន្ន ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជា។

សូមជូនពរដៃគូអាជីវកម្ម ភាគទុនិក និងអតិថិជនទាំងអស់ ទទួលបាននូវសុខភាពល្អមាំមួន វឌ្ឍនភាពប្រកបដោយនិរន្តរភាព និងវិបុលភាពជានិរន្តរ៍។

**ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល**

**អ្នកឧកញ៉ា បណ្ឌិត គួច ម៉េងលី**




# ចំណាប់អារម្មណ៍របស់អគ្គនាយក

តាងនាមគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ខ្ញុំបាទសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះអតិថិជន និងសាធារណជនទាំងអស់ ដែលតែងតែផ្តល់ទំនុកចិត្ត ជឿជាក់ និងគាំទ្រសេវាកម្មហិរញ្ញវត្ថុរបស់គ្រឹះស្ថានយើងខ្ញុំ។ ការជ្រើសរើស និងការបន្តរួមដំណើរជាមួយយើងខ្ញុំ គឺជាកម្លាំងចលករដ៏មានតម្លៃ ដែលជំរុញឱ្យយើងខ្ញុំប្តេជ្ញាចិត្តផ្តល់សេវាកម្មប្រកបដោយ ក្រមសីលធម៌វិជ្ជាជីវៈ តម្លាភាព និងភាពរហ័សទាន់ចិត្តជានិច្ច។

នៅក្នុងឆ្នាំ២០២៥ ថ្វីបើជាននៃវិបត្តិជំងឺកូវីដ-១៩ និងផលប៉ះពាល់ពីជម្លោះរវាងរុស្ស៊ី និងអ៊ុយក្រែន ចាប់ផ្តើមធូរស្រាលជាបណ្តើរៗក្តី ប៉ុន្តែសេដ្ឋកិច្ចសកលនៅតែបន្តស្ថិតក្នុងភាពមិនច្បាស់លាស់។ ការវិវត្តនៃជម្លោះនៅមជ្ឈិមបូព៌ាដែលមានការចូលរួមពីក្រុមប្រដាប់អាវុធនានា បានរីករាលដាលជារូបភាពកាន់តែធំ ដែលបង្កឱ្យតម្លៃប្រេងឥន្ធនៈពិភពលោកហក់ឡើងថ្លៃខ្ពស់ និងបង្កើតជាវិបត្តិថាមពលដ៏ធ្ងន់ធ្ងរ។

ដោយឡែក នៅក្នុងកម្រិតតំបន់ ការប្រែប្រួលនៃបរិយាកាសពាណិជ្ជកម្ម និងសម្ពាធដាច់ដោយឡែកណាមួយនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក៏បានបង្កើតជាការរំខានដល់លំហូរពាណិជ្ជកម្មទ្វេភាគីផងដែរ។ កត្តារួមផ្សំទាំងអស់នេះ បានជះឥទ្ធិពលផ្ទាល់ដល់វិស័យធនាគារ និងហិរញ្ញវត្ថុ ដោយធ្វើឱ្យប៉ះពាល់ដល់ដំណើរការអាជីវកម្ម ការងារកសិកម្ម និងការប្រកបមុខរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលនាំឱ្យបាត់បង់ឱកាសការងារ ប៉ះពាល់ដល់ប្រភពចំណូល និងបង្កជាវិបត្តិហិរញ្ញវត្ថុ។

ទោះបីជាត្រូវប្រឈមមុខនឹងស្ថានភាពសេដ្ឋកិច្ចដ៏តានតឹងទាំងក្នុងស្រុក និងសកលយ៉ាងណាក្តី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី នៅតែរក្សាបាននូវស្ថិរភាព និងវឌ្ឍនភាពប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍តម្លាភាព ទំនុកចិត្ត និងអនុលោមភាពពេញលេញតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់អាជ្ញាធរពាក់ព័ន្ធ។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៥ គ្រឹះស្ថានយើងខ្ញុំសម្រេចបាននូវលទ្ធផលប្រតិបត្តិការដូចខាងក្រោម៖

- អតិថិជនសកម្មសរុប៖ ១.២៤៣ នាក់
- ផលបត្រឥណទានសរុប៖ ៤.៩លានដុល្លារអាម៉េរិក

យើងបាននឹងកំពុងបន្តរួមចំណែកយ៉ាងសកម្មក្នុងការជម្រុញសេដ្ឋកិច្ចសហគមន៍ តាមរយៈការផ្តល់ឥណទាន ដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់អតិថិជន រួមមាន៖ ការពង្រីកអាជីវកម្ម ការសាងសង់ និងជួសជុលគេហដ្ឋាន ការទិញយានយន្ត និងទិញសម្ភារៈប្រើប្រាស់ ការធ្វើកសិកម្ម ព្រមទាំងការផ្តល់ឥណទានសិក្សាដល់សិស្ស-និស្សិត និងអ្នកអាណាព្យាបាល ដែលជាចំណែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់វិស័យអប់រំទាំងក្នុង និងក្រៅប្រទេស។

ដើម្បីបន្តសម្រេចឱ្យបាននូវគោលដៅអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពសម្រាប់ឆ្នាំ២០២៦ គ្រឹះស្ថានបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រគន្លឹះដូចខាងក្រោម៖

- **ពង្រឹងគុណភាពឥណទាន៖** ផ្តោតការយកចិត្តទុកដាក់លើគុណភាពផលបត្រឥណទាន និងការបញ្ចេញឥណទានប្រកបដោយតម្លាភាព ស្របតាមទស្សនវិស័យរយៈពេលវែង។
- **ពង្រឹងការគ្រប់គ្រងផ្ទៃក្នុង និងហានិភ័យ៖** បង្កើនប្រសិទ្ធភាពគ្រប់គ្រងហានិភ័យ និងធានាការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ ព្រមទាំងស្តង់ដារហិរញ្ញវត្ថុទាំងជាតិ និងអន្តរជាតិ។
- **លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ៖** ធានាថាអតិថិជនទាំងអស់ទទួលបានការបម្រើសេវាកម្មពីបុគ្គលិកដែលមានជំនាញច្បាស់លាស់ និងប្រកបដោយក្រមសីលធម៌ខ្ពស់។
- **ជំរុញការប្រើប្រាស់ប្រាក់រៀល៖** ប្តេជ្ញាផ្តល់ឥណទានជាប្រាក់រៀលឱ្យបានយ៉ាងតិច ១០% នៃផលបត្រឥណទានសរុប ស្របតាមគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។
- **អភិវឌ្ឍសមត្ថភាពធនធានមនុស្ស៖** បន្តពង្រឹង និងពង្រីកសមត្ថភាពរបស់បុគ្គលិកតាមរយៈវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងខាងក្រៅគ្រឹះស្ថាន។
- **បរិវត្តកម្មឌីជីថល៖** ធ្វើបច្ចុប្បន្នភាពប្រព័ន្ធធនាគារស្នូល (Core Banking System) ឱ្យស្របទៅតាមយុគសម័យឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពការងារ ភាពងាយស្រួល ល្បឿនលឿនរហ័ស និងសុវត្ថិភាពខ្ពស់ ព្រមទាំងរួមចំណែកគាំទ្រគោលនយោបាយសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតផលិតផល និងសេវាកម្មថ្មីៗ។

ជាទីបញ្ចប់ តាងនាមគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ខ្ញុំបាទសូមសម្តែងនូវការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ដែលតែងតែផ្តល់ការណែនាំ និងគាំទ្រយ៉ាងពេញទំហឹងដល់ដំណើរការប្រតិបត្តិការរបស់គ្រឹះស្ថាន។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអាជីវកម្ម និងអតិថិជនទាំងអស់ សម្រាប់ការផ្តល់ទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។

សូមជូនពរដៃគូអាជីវកម្ម ភាគទុនិក និងអតិថិជនទាំងអស់ ទទួលបាននូវសុខភាពល្អមាំមួន វឌ្ឍនភាពប្រកបដោយនិរន្តរភាព និងវិបុលភាពជានិរន្តរ៍៕

**អគ្គនាយក**



**លោក ឃុន ដាវុធ**

# ប្រវត្តិរបស់ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

**២០០៥** ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី គឺជាគម្រោងមួយក្នុងចំណោមគម្រោងជាច្រើន របស់មូលនិធិ ម៉េងលីជេ.គួច ដែលជាមូលនិធិមិនស្វែងរកប្រាក់ចំណេញ។



២០០៥

២០១៣



**២០១៣** ដើម្បីសម្រេចបានតាមទស្សនវិស័យ របស់ខ្លួន "*...ធ្វើឱ្យជីវិតកាន់តែប្រសើរឡើង*" ហើយឥណទានក៏មានកំណើនកើនឡើងផងដែរនោះ គម្រោងមូលនិធិនេះ ក៏បានផ្លាស់ប្តូរមកជាអង្គការប្រជាជាតិហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មពីក្រសួងមហាផ្ទៃ ផ្តល់ឥណទានជាមួយអត្រាការប្រាក់ទាប ជូនដល់សាធារណៈជនគ្រប់ស្រទាប់វណ្ណៈ។



២០១៦

**២០១៦** អង្គការប្រជាជាតិហិរញ្ញវត្ថុ បានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលមានលេខសម្គាល់ ម.ហ៧៣ ហើយបានប្តូរឈ្មោះជា"**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**"

២០១៧ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ទទួលអាជ្ញាបណ្ណបង្កើតសាខា រួមមាន៖ សាខារាជធានីភ្នំពេញ សាខាស្រុកបាទី សាខាខេត្តកំពង់ស្ពឺ និងសាខាស្រុកជើងព្រៃ។

## ២០១៧

## ២០១៨

២០១៨ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានផ្លាស់ប្តូរអាសយដ្ឋានការិយាល័យកណ្តាល៖

- **ទីស្នាក់ការចាស់:** លេខB៧៨ ផ្លូវលេខ១៩៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។
- **ទីស្នាក់ការបច្ចុប្បន្ន:** អគារលេខ១៣២ ផ្លូវលេខ១៩៣ កែងផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

## ២០១៩

២០១៩ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងធនាគារស្នូល ពីប្រព័ន្ធហ្វាយផ្លាស (FIPLUS System) ហើយប្តូរមកប្រើប្រាស់ប្រព័ន្ធមរកត (Morakot System) វិញ។

២០២១ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធធនាគារស្នូល ឱ្យមានសមត្ថភាពពេញលេញ ដោយអនុលោមតាមរបាយការណ៍ហិរញ្ញវត្ថុ ស្តង់ដារអន្តរជាតិនៅកម្ពុជាសម្រាប់សហគ្រាស ធុនតូច និងមធ្យម(CIFRS for SME)។



២០២១

២០២៣



២០២៣ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ដាក់ឱ្យសាកល្បងអនុវត្តប្រព័ន្ធឌីជីថល Loan Origination System (LOS) ទៅក្នុងប្រព័ន្ធធនាគារស្នូល មរកត (Morokot System)។



២០២៤

២០២៤ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានចុះអនុស្សរណៈយោគយល់គ្នា ក្នុងការផ្តល់ឥណទានសិក្សាអប់រំទាំងចំណេះដឹងទូទៅ និងថ្នាក់ឧត្តមសិក្សា។

# សមិទ្ធផល របស់ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

ចំនួនអតិថិជន




ផលបត្រឥណទានសរុប (គិតជាដុល្លារ)




ចំនួនសាខា




ចំនួនបុគ្គលិក




ចំនួនទ្រព្យសកម្ម(គិតជាដុល្លារ)




ផលចំណេញ (គិតជាដុល្លារ)




ភាគរយនៃឥណទានជាប្រាក់រៀល




អតិថិជនប្រាក់រៀល



| របាយការណ៍សមិទ្ធផល | ២០២៥ | ២០២៤ | ២០២៣ |
|---|---|---|---|
| ខេត្ត | ៥ | ៥ | ៥ |
| ការិយាល័យ | ៤ | ៤ | ៤ |
| បុគ្គលិក | ៦៤ | ៦០ | ៦៣ |
| អតិថិជន (KHR) | ៣៨៣ | ៣៨៩ | ៤៧០ |
| អតិថិជន (USD) | ៨៦០ | ៨៣៦ | ៩០៧ |
| សរុបអតិថិជន | ១.២៤៣ | ១.២៣៤ | ១.៣៧៧ |
| ផលប័ត្រឥណទាន KHR (លានរៀល) | ២.១០២,៥០ | ២.០២១,១៤ | ២.៤៤៩,២១ |
| ផលប័ត្រឥណទាន USD (លានដុល្លារ) | ៤.៤៦៨ | ៤.៦៤៧ | ៤.៣៧៩ |
| សរុបផលប័ត្រឥណទាន (លានដុល្លារ) | ៤.៩៩២ | ៥.១៤៩ | ៤.៩៧៩ |
| ផលប័ត្រឥណទានហានិភ័យ (NPL) | ៦៥២.៨៥០,២៦ | ៧១៩.៧៥៣,៥៣ | ៧១៣.៧៣៥,០២ |
| ភាគរយផលប័ត្រឥណទានដែលមានហានិភ័យ(NPL) | ១៣,០៨% | ១៣,៩៨% | ១៤,៣៣% |
| ផលប័ត្រឥណទានលុបចេញពីបញ្ជី | - | ៦៧៧.១៨០ | - |
| ផលប័ត្រឥណទានលុបចេញពីបញ្ជី(%) | - | ១៣,១៥% | - |
| ស្វ័យភាពគ្រប់គ្រាន់ផ្នែកប្រតិបត្តិការ(OSS) | ៨៩,៧៣% | ៨២,២៧% | ៩២,៩៤% |
| អនុបាតសោធនភាព(CAR) | ៤៩,១៧% | ៤៩,៨១% | ៥៧,៨២% |
| ទ្រព្យសកម្មសរុប(ដុល្លារ) | ៥.៦៥៥.៣៨៩ | ៦.៣១៦.១៥៤ | ៥.៨៤៣.៧៣៨ |
| បំណុលសរុប(ដុល្លារ) | ២.៥៩៦.៦៨២ | ៣.១៩២.៥១៤ | ២.៥៥៤.៩៧៤ |
| ប្រាក់ចំណេញមុនពេលបង់ពន្ធ(ដុល្លារ) | (២៨.៤៥៥) | (១៩១.៥៥៦) | (៩.១៤១) |
| ប្រាក់ចំណេញក្រោយពេលបង់ពន្ធ(ដុល្លារ) | (៦៤.៩៣២) | (១៦៥.១២៤) | (៦.២៤៦) |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្មសរុប(ROA) | (១,១៥%) | (២,៦១%) | (០,១១%) |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន(ROE) | (២,១២%) | (៥,២៩%) | (០,១៩%) |
| អត្រាប្តូរប្រាក់ | ៤.០១៣ | ៤.០២៥ | ៤.០៨៥ |

# ការចូលរួមបរិច្ចាក

ឆ្លងកាត់ស្ថានភាពប្រឈមនៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ នាពេលកន្លងមក ដែលបានជះឥទ្ធិពល និងបង្កការលំបាកដល់បងប្អូនកងទ័ពជួរមុខ ព្រមទាំងប្រជាពលរដ្ឋ ជាច្រើនគ្រួសាររស់នៅតាមតំបន់ព្រំដែន ដែលតម្រូវឱ្យផ្លាស់ប្តូរទីលំនៅ ជាបណ្តោះអាសន្ន ដោយក្តីព្រួយបារម្ភ។ **ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី** បានចូលរួមបរិច្ចាកថវិកាឧបត្ថម្ភ តាមរយៈ **សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា** ក្នុងយុទ្ធនាការ **"មូលនិធិគាំទ្រកងទ័ពជួរមុខ និងប្រជាជនជម្លៀសពីលំនៅដ្ឋាន"**។

ទោះបីជាការចូលរួមចំណែកនេះមានទំហំមិនធំធេងក្តី ប៉ុន្តែបានស្តែងចេញយ៉ាងច្បាស់ពីទឹកចិត្តស្រឡាញ់ជាតិមាតុភូមិ និងស្មារតីសាមគ្គីភាពយ៉ាងមុតមាំ របស់គ្រឹះស្ថានយើងខ្ញុំ ក្នុងការរួមសុខរួមទុក្ខ និងចែករំលែកការលំបាកជាមួយគ្នាក្នុងគ្រាអាសន្ន។


សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

លិខិតថ្លែងអំណរគុណ
ជូនចំពោះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

ដែលបានចូលរួមបរិច្ចាកថវិកាចំនួន ៥០០ ដុល្លារ
ក្នុង **"មូលនិធិគាំទ្រកងទ័ពជួរមុខ និងប្រជាជនជម្លៀសពីលំនៅដ្ឋាន"**
ដែលកំពុងរងផលប៉ះពាល់នៅតំបន់ព្រំដែន។ ទឹកចិត្តសប្បុរសធម៌ និងក្តីមេត្តាដ៏ជ្រាលជ្រៅរបស់
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ "ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី"**
ក្នុងបុព្វហេតុមនុស្សធម៌នេះបានផ្តល់ការគាំទ្រ និងក្តីសង្ឃឹមយ៉ាងខ្លាំងដល់វីរកងទ័ពជួរមុខ
ដែលកំពុងប្រយុទ្ធការពារបូរណភាពទឹកដី និងជួយសម្រាលបន្ទុកដល់ប្រជាជន
ដែលកំពុងជម្លៀសខ្លួនទៅកាន់ទីកន្លែងសុវត្ថិភាព។

**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះជំនួយមនុស្សធម៌ និងទឹកចិត្តសប្បុរស
របស់លោក លោកស្រីដែលបានចូលរួមចំណែកក្នុងគ្រាដ៏លំបាកនេះ។

ប្រធានក្រុមប្រឹក្សាភិបាល សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ក្នុងឱកាសដ៏ថ្លៃថ្លានេះ គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ទាំងអស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី សូមសម្តែងនូវការដឹងគុណ និងកោតសរសើរយ៉ាងជ្រាលជ្រៅបំផុត ចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរកងទ័ពជួរមុខទាំងអស់ ដែលបានលះបង់កម្លាំងកាយចិត្ត និងពលិកម្មគ្រប់បែបយ៉ាង ដើម្បីការពារបូរណភាពទឹកដី សន្តិសុខជាតិ និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋកម្ពុជា។

ជាទីបញ្ចប់ យើងខ្ញុំទាំងអស់គ្នា សូមគោរពជូនពរចំពោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ព្រមទាំងបងប្អូនវីរកងទ័ពជួរមុខទាំងអស់ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន និងប្រាជ្ញាញាណភ្លឺថ្លា ដើម្បីបន្តបេសកកម្មដឹកនាំ និងការពារមាតុភូមិកម្ពុជា ឱ្យរក្សាបាននូវស្ថិរភាព សន្តិភាព និងការអភិវឌ្ឍរីកចម្រើនគ្រកាលជានិរន្តរ៍។

# បណ្ដាញសាខា

## ១. ការិយាល័យកណ្ដាល

អគារលេខ១៣២ ផ្លូវលេខ១៩៣ កែងផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

អ៊ីមែល : info@prasethpheapfinance.com.kh

ទូរសព្ទ : ០២៣ ៩៧ ០០០០ / ០១៧ ៦៤២ ៣១៩

គេហទំព័រ : www.prasethpheapfinance.com.kh

## ២. សាខាក្រុមហ៊ុនក្នុងស្រុក (ខណ្ឌបឹងកេងកង - សង្កាត់ទួលស្វាយព្រៃទី១)

អគារលេខ១៣២ ផ្លូវលេខ១៩៣ កែងផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

អ៊ីមែល : pnpbm@prasethpheapfinance.com.kh

ទូរសព្ទ : ០៨៦ ២២២ ៨១៣ / ០៨៦ ៥៦៧ ៦៨៩

គេហទំព័រ : www.prasethpheapfinance.com.kh

## ៣. សាខាក្រុមហ៊ុនក្នុងស្រុក (ស្រុកបាទី - ឃុំចំបក់)

ក្បាលដីលេខ១២៦៦ ផ្លូវជាតិលេខ២ ភូមិបចាម ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។

អ៊ីមែល : btibm@prasethpheapfinance.com.kh

ទូរសព្ទ : ០៨៦ ២២២ ៨១២ / ០៨៦ ៥៦៧ ៨១៧

គេហទំព័រ : www.prasethpheapfinance.com.kh

## ៤. សាខាក្រុមហ៊ុនក្នុងស្រុក (ខេត្តកំពង់ស្ពឺ)

ក្បាលដីលេខ៥២៥ ផ្លូវជាតិលេខ៤ ភូមិអង្គសេរី សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

អ៊ីមែល : kpsbm@prasethpheapfinance.com.kh

ទូរសព្ទ : ០៨៦ ២២២ ៧៥១ / ០៨៦ ៥៦៧ ៨០៣

គេហទំព័រ : www.prasethpheapfinance.com.kh

## ៥. សាខាក្រុមហ៊ុនក្នុងស្រុក (ស្រុកជើងព្រៃ - ឃុំសូទិព្វ)

ផ្លូវជាតិលេខ៦ ភូមិតាសែន ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

អ៊ីមែល : chpbm@prasethpheapfinance.com.kh

ទូរសព្ទ : ០៨៦ ២២២ ៧៥៨ / ០៨៦ ៥៦៧ ៨១៣

គេហទំព័រ : www.prasethpheapfinance.com.kh

# ការគ្របដណ្ដប់តំបន់ប្រតិបត្តិការ



# ផលិតផល និងសេវាកម្ម

## ឥណទានអាជីវកម្ម

ឥណទានអាជីវកម្មបង្កើតឡើង ក្នុងគោលបំណងសម្រាប់ឱ្យអាជីវករ ពាណិជ្ជករ ខ្នាតតូច និងមធ្យម ដែលមានតម្រូវការដើមទុន ក្នុងការពង្រីកអាជីវកម្ម ឬបន្ថែមដើមទុន។ អាចខ្ចីបានរហូតដល់៥០.០០០ ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់១២០ខែ។





## ឥណទានអចលទ្រព្យ

ឥណទានអចលនទ្រព្យបង្កើតឡើង ក្នុងគោលបំណងផ្តល់ជាប្រភពហិរញ្ញវត្ថុ ជាលក្ខណៈឯកត្តជនយ៉ាងសម្បូរបែប ជូនអតិថិជន ដើម្បីយកទៅទិញដីលំនៅដ្ឋាន ទិញផ្ទះ សាងសង់ ឬជួសជុល ឬកែលម្អគេហដ្ឋាន។ល។ អាចខ្ចីបានរហូតដល់ ២០.០០០ដុល្លារអាមេរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់ ៧២ខែ។

## ឥណទានកសិកម្ម

ឥណទានកសិកម្មបង្កើតឡើង ក្នុងគោលបំណងផ្តល់ប្រភពហិរញ្ញវត្ថុជាលក្ខណៈឯកត្តជន យ៉ាងសម្បូរបែបជូនអតិថិជន ដើម្បីយកទៅទិញ ជាគ្រាប់ពូជ ការចិញ្ចឹមសត្វ ការនេសាទ ទិញឧបករណ៍ទាក់ទងវិស័យកសិកម្ម ទិញដីសម្រាប់ធ្វើកសិកម្ម ។ល។ អាចខ្ចីបានរហូតដល់ ២០.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់ ៧២ខែ។





## ឥណទានយានយន្ត

ឥណទានយានយន្តបង្កើតឡើង ក្នុងគោលបំណងផ្តល់ជាប្រភពហិរញ្ញវត្ថុជាលក្ខណៈឯកត្តជនយ៉ាងសម្បូរបែបជូនអតិថិជន ដើម្បីយកទៅ ទិញម៉ូតូ រថយន្ត។ល។ អាចខ្ចីបានរហូតដល់ ២០.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់ ៧២ខែ។

## ឥណទានសិក្សាអប់រំ

ឥណទានសិក្សាអប់រំបង្កើតឡើង ក្នុងគោលបំណងបង់ថ្លៃសិក្សាថ្នាក់ចំណេះដឹងទូទៅ ថ្នាក់ឧត្តមសិក្សា ក្រោយឧត្តមសិក្សា ឬការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំឆ្នាំ ឬប្រចាំឆមាស ឬមួយវគ្គសិក្សា ឬទិញឧបករណ៍ សម្ភារៈ ឬថ្លៃសេវាកម្មផ្សេងៗទាក់ទងការសិក្សាល។ អាចខ្ចីបានរហូតដល់ ១០.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់៦០ខែ។





## ឥណទានសម្ភារៈប្រើប្រាស់

ឥណទានសម្ភារៈប្រើប្រាស់បង្កើតឡើង ក្នុងគោលបំណងផ្តល់ជាប្រភពហិរញ្ញវត្ថុ ជាលក្ខណៈឯកត្តជន យ៉ាងសម្បូរបែបជូនអតិថិជន ដើម្បីយកទៅទិញសម្ភារៈប្រើប្រាស់ដូចជា៖ ទូរសព្ទដៃ ទូរទស្សន៍ ម៉ាស៊ីនថតរូប ម៉ាស៊ីនបោកគក់សម្លៀកបំពាក់ ម៉ាស៊ីនត្រជាក់ ទូរទឹកកក សម្ភារៈប្រើប្រាស់ផ្សេងៗទៀត។ អាចខ្ចីបានរហូតដល់ ១០.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់៦០ខែ។

## ឥណទានសម្រាប់បុគ្គលិកការិយាល័យ

ឥណទានសម្រាប់បុគ្គលិកការិយាល័យបង្កើតឡើង ក្នុងគោលបំណងផ្តល់ឥណទាន ដល់បុគ្គលិកពេញសិទ្ធិ និងកំពុងបម្រើការងារ ដែលមានតួនាទីមិនស្ថិតក្នុងហានិភ័យខ្ពស់ និងមានអតីតភាពការងារចាប់ពី ០៦ខែឡើងទៅ។ អាចខ្ចីបានរហូតដល់ ៣.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់ ២៤ខែ។





## ឥណទានបុគ្គលិក

ឥណទានបុគ្គលិក គឺកម្ចីផ្តល់ជូនបុគ្គលិកដែលបម្រើការងារ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ក្នុងគោលបំណងទិញសម្ភារៈប្រើប្រាស់ និងតម្រូវការផ្សេងៗ អាចខ្ចីបានរហូតដល់ ៣០.០០០ដុល្លារអាម៉េរិក ឬសមមូលជាប្រាក់រៀល និងរយៈពេលកម្ចីបានរហូតដល់ ១២០ខែ។

# ភាគទុនិក

| ឈ្មោះភាគទុនិក | ចំនួនភាគហ៊ុន | ចំនួនទឹកប្រាក់គិតជាដុល្លារ | ភាគរយ |
|---|---|---|---|
| អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ២.៨៧៣.១៧៨ | ២.៨៧៣.១៧៨ | ៩៨,៥៤% |
| លោក ឡុង ពិសី | ៤២.៥៨៨ | ៤២.៥៨៨ | ១,៤៦% |
| **សរុប** | **២.៩១៥.៧៦៦** | **២.៩១៥.៧៦៦** | **១០០%** |

១ភាគហ៊ុន = ១ដុល្លារអាម៉េរិក

# រចនាសម្ព័ន្ធគ្រប់គ្រង



# ក្រុមប្រឹក្សាភិបាល

## អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល



អ្នកឧកញ៉ា ជាអ្នកឯកទេសអប់រំ វេជ្ជបណ្ឌិត ជនស្នេហាជាតិ និងជាសហគ្រិនមួយរូប។ បច្ចុប្បន្ន អ្នកឧកញ៉ា ជាស្ថាបនិកនិងប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។អ្នកឧកញ៉ា ក៏ជាស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន។ ស្ថាប័នអប់រំនេះមាន មជ្ឈមណ្ឌលភាសា អេ អាយ អាយ (Aii) សាលារៀន អន្តរទ្វីប អាមេរិកាំង (AIS) និងសូហ្គូ (SOGO) ដែលផ្តោតសំខាន់លើការអប់រំ ការរីកចម្រើននៃសង្គម និងការអភិវឌ្ឍសហគមន៍នៅក្នុងប្រទេសកម្ពុជា។

បច្ចុប្បន្ន អ្នកឧកញ៉ាមានតំណែងដ៏មានឥទ្ធិពលមួយចំនួន ដូចជា៖ សមាជិកទីប្រឹក្សា និងសហអនុប្រធានក្រុមការងារផ្នែកសុខាភិបាល (ចាប់ពីឆ្នាំ២០២៣) សហអនុប្រធានក្រុមការងារផ្នែកអប់រំ (ចាប់ពីឆ្នាំ ២០១៩) នៃសភាពាណិជ្ជកម្ម កម្ពុជា។ អ្នកឧកញ៉ាក៏មានតំណែងជា ទីប្រឹក្សាកិត្តិយស នៃសមាគមសហគ្រិនស្ត្រីកម្ពុជា សមាជិកក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព សហស្ថាបនិក និងទីប្រឹក្សា នៃសហព័ន្ធសេវាអប់រំនៅកម្ពុជា សមាជិកស្ថាបនិក និងក្រុមប្រឹក្សាភិបាលនៃអង្គការតម្លាភាពកម្ពុជា ប្រធានស្ថាបនិកកិត្តិយស នៃសហព័ន្ធកីឡាល្បុក្កតោកម្ពុជា ឧត្តមទីប្រឹក្សា គណៈសង្ឃនាយក គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា។

### ប្រវត្តិសិក្សា

អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី មានស្រុកកំណើតនៅខេត្តបាត់ដំបង ហើយបានរស់នៅ និងទទួលបានការអប់រំនៅក្នុងសហរដ្ឋអាម៉េរិក។ អ្នកឧកញ៉ា បានបញ្ចប់ការសិក្សាផ្នែក Pre-Med Studies នៅសាកលវិទ្យាល័យ University of California at Berkeley និងទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកសុខភាពសាធារណៈ ពីសាកល

វិទ្យាល័យ Massachusetts ក្រុង Amherst និងទទួលបានសញ្ញាបត្រវេជ្ជបណ្ឌិតវេជ្ជសាស្ត្រ ជំនាញវេជ្ជសាស្ត្រទូទៅពីសាកលវិទ្យាល័យ Spartan Health Sciences។ អ្នកឧកញ៉ា បានបញ្ចប់ការហ្វឹកហ្វឺនផ្នែកវេជ្ជសាស្ត្រនៅមន្ទីរពេទ្យ នៃសាកលវិទ្យាល័យ អៀលលីណយ ទីក្រុងឈីកាហ្គោ សហរដ្ឋអាម៉េរិក និងការហ្វឹកហ្វឺនក្រោយថ្នាក់វេជ្ជបណ្ឌិត ក្នុងតួនាទី ជាទីប្រឹក្សាសុខភាពសាធារណៈ នៃគម្រោងសមាហរណកម្មនៃការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ(ស.ព.ជ.ក) អង្គការដៃគូសម្រាប់អភិវឌ្ឍន៍ ជាអង្គការមួយដែលមានមូលដ្ឋាននៅ រដ្ឋម៉ារីឡែន សហរដ្ឋអាម៉េរិក និងមានសកម្មភាពក្នុងប្រទេសកម្ពុជា។

## ដំណើរអាជីព

មុនពេលវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០០២ អ្នកឧកញ៉ា បានបម្រើការងារលើតួនាទីជាសាស្ត្រាចារ្យវិទ្យាសាស្ត្រ បង្រៀននៅដេប៉ាតឺម៉ង់ វិទ្យាសាស្ត្រស្តីពីរូបរាងកាយ និងជីវិត នៃមហាវិទ្យាល័យ Cleveland Chiropractic ក្នុងរដ្ឋ California។ នៅពេលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ អ្នកឧកញ៉ាបានបំពេញតួនាទីសំខាន់ៗមួយចំនួន នៅក្នុងវិស័យអប់រំ រួមមានដូចជា៖ សាស្ត្រាចារ្យរង នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា អនុប្រធានគណៈកម្មការអប់រំ ស្ថាបនិកព្រឹទ្ធបុរស និងសាស្ត្រាចារ្យរង ផ្នែកសុខភាពសាធារណៈ នៃមហាវិទ្យាល័យសុខភាពសាធារណៈ នៅសាកលវិទ្យាល័យកម្ពុជា។ ក្នុងឆ្នាំ២០០៥ អ្នកឧកញ៉ាបានបង្កើត ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ជាស្ថាប័នអប់រំដែលបានរីកចម្រើនជាគោលដ៏សំខាន់ នៃឧត្តមភាពក្នុងការអប់រំ និងផលជះជាវិជ្ជមានដល់សង្គមនៅក្នុងប្រទេសកម្ពុជា។

## ការស្នេហាមនុស្សជាតិ និងផលជះ

លោកវេជ្ជបណ្ឌិត គួច ម៉េងលី ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ក្រោមការលះបង់របស់លោកចំពោះការអភិវឌ្ឍសហគមន៍ តាមយៈវិស័យអប់រំ សុខាភិបាល និងសេវាកម្មសង្គម។ ស្ថាប័នអប់រំរបស់លោក គឺក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ដែលតែងទទួលបានការកោតសរសើរយ៉ាងច្រើនទាំងនៅលើថ្នាក់ជាតិ និងអន្តរជាតិ ចំពោះការចូលរួមចំណែកដ៏ធ្ងើមរបស់ខ្លួនលើវិស័យទាំងនេះ ដែលបានពង្រឹងបន្ថែមកេរ្តិ៍ដំណែលរបស់លោក ក្នុងនាមជាអ្នកដឹកនាំដែលមានចក្ខុវិស័យ និងអ្នកផ្លាស់ប្ដូរមួយរូបនៅក្នុងប្រទេសកម្ពុជា។ ការប្ដេជ្ញាចិត្តពេញមួយជីវិតរបស់លោកវេជ្ជបណ្ឌិត គួច ម៉េងលី ក្នុងការផ្ដល់សិទ្ធិអំណាចដល់សហគមន៍ តាមរយៈការអប់រំ សុខភាពសាធារណៈ និងសប្បុរសធម៌ នៅតែបន្តជំរុញ និងផ្លាស់ប្ដូរជីវិតប្រជាជននៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស។



## លោក គង់ វ៉ាវ៉ា អភិបាលឯករាជ្យ

លោក គង់ វ៉ាវ៉ា មានតួនាទីជាអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី តាំងពីឆ្នាំ២០១៨។ លោកក៏ជាអភិបាលឯករាជ្យ នៃក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិនផងដែរ។ លោកមានបទពិសោធជិត ៤០ឆ្នាំ លើការដឹកនាំ និងគ្រប់គ្រង ក្នុងវិស័យអាជីវកម្មផ្សេងៗជាច្រើនដូចជាៈ កាសែត ទស្សនាវដ្តី ការវិនិយោគ ការបោះពុម្ពប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ វិស័យកាត់ដេរ ធនាគារ សណ្ឋាគារ កាស៊ីណូ ជានាវ៉ាប់រងទូទៅ សម្ភារៈសំណង់ នាំចេញ និងនាំចូល( Export & Import Company )អាហារ និងភេសជ្ជៈ ការវាយតម្លៃលើផលប៉ះពាល់ខាងបរិស្ថាន វិស័យអចលនទ្រព្យ និងវិស័យអប់រំ។ លោកទទួលបានចំណេះដឹងទូលំទូលាយទាំងក្នុង និងក្រៅប្រទេសដូចជាៈ ទូរីន អ៊ីតាលី និងហាវ៉ៃ សហរដ្ឋអាម៉េរិក ហើយលោកក៏ធ្លាប់ត្រូវបានគេអញ្ជើញជាគ្រូបង្គោល ជាវាគ្មិនក្នុងវគ្គហ្វឹកហ្វឺន សិក្ខាសាលាដែលបានធ្វើឡើងក្នុង និងក្រៅប្រទេសផងដែរ។

## លោក ឡុង ពិសី អភិបាល



លោក ឡុង ពិសី គឺជាភាគទុនិក និងអភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលមួយរូប លោកមានតួនាទីយ៉ាងសំខាន់មួយក្នុងការត្រួតពិនិត្យ លើការរៀបចំគម្រោង និងពង្រឹងអាជីវកម្មរបស់គ្រឹះស្ថាន ដែលពាក់ព័ន្ធជាមួយនឹងគម្រោងថវិកាប្រចាំឆ្នាំ និងធ្វើយ៉ាងណាឱ្យប្រតិបត្តិការអាជីវកម្មមួយនេះដំណើរការទៅបានរលូន។ លោកបានចាប់ផ្តើមតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលចាប់តាំងពីឆ្នាំ២០១៨។ លោកមានបទពិសោធជាច្រើនឆ្នាំ ក្នុងការដឹកនាំ និងគ្រប់គ្រង ក្នុងវិស័យផ្សេងៗជាច្រើន ជាពិសេស វិស័យអប់រំ។ លោក ឡុង ពិសី បានបញ្ចប់បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស នៅក្នុងឆ្នាំ២០០៦ នៅសកលវិទ្យាល័យបៀលប្រាយ។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ក្នុងឆ្នាំ២០២២ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រផងដែរ។

# គណៈគ្រប់គ្រង

## លោក យុន ដារ៉ុជ អគ្គនាយក



លោក យុន ដារ៉ុជ បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី តាំងពីឆ្នាំ២០២១ ក្នុងតួនាទី ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ បន្ទាប់មកលោកត្រូវបានតែងតាំង ជាអគ្គនាយកផ្នែកហិរញ្ញវត្ថុ អគ្គនាយកស្តីទីផ្នែកប្រតិបត្តិការ អគ្គនាយកស្តីទី និងបច្ចុប្បន្នលោកមានតួនាទីជា អគ្គនាយក។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ និងបរិញ្ញាបត្រផ្នែកគណនេយ្យ។ លោកមានបទពិសោធជិត២០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ លើការគ្រប់គ្រងឥណទាន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងសាខា និងការគ្រប់គ្រងគណនេយ្យសាខា លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលបីខែលើបទប្បញ្ញត្តិ និងការប្រតិបត្តិតាមដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជាផងដែរ។

## លោក ឯក ណារិទ្ធ ប្រធាននាយកដ្ឋានហានិភ័យ និងដោះស្រាយបំណុល



លោក ឯក ណារិទ្ធ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម និងបរិញ្ញាបត្រផ្នែកលក់ និងទីផ្សារ។ លោកបានចាប់ផ្តើមការងារ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី តាំងពីឆ្នាំ២០២២ លោកមានបទពិសោធជិត២០ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជា។ លោកក៏បានបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងស្រុកផ្សេងៗ លើវគ្គទាក់ទងនឹងការគ្រប់គ្រងស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ការគ្រប់គ្រងហានិភ័យឥណទាន គ្រូបង្គោលបណ្តុះបណ្តាលបុគ្គលិក ការគ្រប់គ្រងសាខា ជំនាញលក់ ការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មខ្នាតតូច និងមធ្យមវាយតម្លៃវត្ថុបញ្ចាំ និងភាពជាអ្នកដឹកនាំ។

## លោក ឆយ វ៉ាន់ដេត ប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល



លោក ឆយ វ៉ាន់ដេត បានចូលបម្រើការងារ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ចាប់តាំងពីខែធ្នូ ឆ្នាំ២០២១ មានតួនាទីជាប្រធានផ្នែកធនធានមនុស្សនិងរដ្ឋបាល ក្នុងឆ្នាំ២០២៣ លោកបានផ្លាស់ប្តូរតួនាទីជាប្រធាននាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យ លោកមានបទពិសោធជិត២០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ លោកបានធ្លាប់បានបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន។ លោកមានបទពិសោធ ក្នុងការគ្រប់គ្រងធនធានមនុស្សជាច្រើនឆ្នាំ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ជាច្រើនដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ធនធានមនុស្ស។

## លោក គាត សុខគីម ប្រធាននាយកដ្ឋានឥណទាន



លោក គាត សុខគីម បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលសុី នៅដើមឆ្នាំ២០២៣ ក្នុងតួនាទីជាប្រធានផ្នែកឥណទាន ក្នុងឆ្នាំ២០២៥ លោកបានផ្លាស់ប្តូរតួនាទីជា ប្រធាននាយកដ្ឋានឥណទាន លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញព័ត៌មានវិទ្យា។ លោកមានបទពិសោធការងារច្រើនជាង១០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ រួមមាន៖ ការគ្រប់គ្រងហានិភ័យឥណទាន ជាគ្រូបង្គោលបណ្តុះបណ្តាលបុគ្គលិក ការគ្រប់គ្រងសាខា ជំនាញលក់ ការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម ការវាយតម្លៃវត្ថុបញ្ចាំ និងភាពជាអ្នកដឹកនាំ។ លើសពីនេះទៀតលោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនពាក់ព័ន្ធនឹងការគ្រប់គ្រងស្ថាប័នក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារផងដែរ។

## លោក លី គឹមងន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក លី គឹមងន បានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលសុី នៅក្នុងឆ្នាំ២០២២ តួនាទីជា ប្រធានផ្នែកសវនកម្មផ្ទៃក្នុង លោកបានផ្លាស់ប្តូរតួនាទីជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងឆ្នាំ២០២៤។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញធនាគារ និងហិរញ្ញវត្ថុ។ មុនពេលចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលសុី លោកមានបទពិសោធជាង ១១ឆ្នាំ ទាក់ទងការងារផ្នែកសវនកម្មផ្ទៃក្នុង គណនេយ្យករ មន្ត្រីឥណទាន ធនធានមនុស្ស និងរដ្ឋបាល( ទាំងវិស័យមីក្រូហិរញ្ញវត្ថុ វិស័យអចលនទ្រព្យ វិស័យអប់រំ និងវិស័យកសិកម្ម)។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងផ្នែកសវនកម្ម និងគ្រប់គ្រងហានិភ័យ។

## លោក ស៊ាង ឆាយ ប្រធានផ្នែកព័ត៌មានវិទ្យា



លោក ស៊ាង ឆាយ បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលសុី តាំងពីឆ្នាំ២០២៤។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងអនុបណ្ឌិត ផ្នែកការបង្កើតសូហ្វវែរ(Software Development)។ លោកមានបទពិសោធជាង១០ ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ លើការគ្រប់គ្រងប្រព័ន្ធធនាគារស្នូល ឡូជីស្ទិក និងឧស្សាហកម្មប្រេង។ លោកបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និងធនាគារ ការគ្រប់គ្រងការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍បុគ្គលិក។

## កញ្ញា សី ធីតា ប្រធានផ្នែកគណនេយ្យហិរញ្ញវត្ថុ



កញ្ញា សី ធីតា មានតួនាទីជាប្រធានគណនេយ្យហិរញ្ញវត្ថុ។ កញ្ញាបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី តាំងពីឆ្នាំ២០១៤ ដែលមានតួនាទីជាជំនួយការបេឡាធិការ ប្រចាំសាខារាជធានីភ្នំពេញ។ ដោយការខិតខំប្រឹងប្រែង កញ្ញាបានផ្លាស់ប្តូរតួនាទីជាច្រើននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី។ កញ្ញាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ ហើយបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដែលទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ។

## អ្នកស្រី យឹម ស្រីឡុង មន្ត្រីគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមជាន់ខ្ពស់



អ្នកស្រី យឹម ស្រីឡុង បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី នៅដើមខែកញ្ញា ឆ្នាំ២០២០ អ្នកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញធនាគារ និងហិរញ្ញវត្ថុ។ អ្នកស្រី មានបទពិសោធជាង ០៨ឆ្នាំ ផ្នែកប្រតិបត្តិតាមក្នុងវិស័យហិរញ្ញវត្ថុ។ អ្នកស្រីទទួលបានវិញ្ញាបនបត្របទប្បញ្ញត្តិ និងការប្រតិបត្តិតាមដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ព្រមទាំងបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដែលទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ។

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំឡើងយ៉ាងទៀងទាត់ប្រចាំត្រីមាស ឬរៀងរាល់០៤(បួន)ដង ក្នុងមួយឆ្នាំ។ ក្នុងករណីពិសេសដែលកើតមានឡើង ក្រុមប្រឹក្សាភិបាលនឹងកោះប្រជុំវិសាមញ្ញតាមស្ថានភាពជាក់ស្តែង។ សម្រាប់ការប្រជុំគណៈកម្មការសវនកម្ម និងគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម យ៉ាងតិច០២(ពីរ)ដង ក្នុងមួយឆ្នាំ។






Jan 8, 2026
© PF



No Recording




# ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

## ការបណ្តុះបណ្តាលផ្ទៃក្នុង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី តែងតែផ្តល់វគ្គបណ្តុះបណ្តាលផ្ទៃក្នុងជូនបុគ្គលិកទាំងអស់ ដើម្បីឱ្យបុគ្គលិកទាំងអស់មានការយល់ដឹងអំពី គោលការណ៍ នីតិវិធី ទស្សនៈវិស័យ ចក្ខុវិស័យរបស់គ្រឹះស្ថាន ក្រមសីលធម៌ការងារប្រកបដោយវិជ្ជាជីវៈ បណ្តុះនូវផ្នត់គំនិត ព្រមទាំងចំណេះជំនាញដើម្បីអនុវត្តការងារ។ ការផ្តល់វគ្គបណ្តុះបណ្តាលផ្ទៃក្នុងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី សម្រាប់ឆ្នាំ២០២៥ រួមមានដូចខាងក្រោម៖

- **ផ្នែកឥណទាន**

  ប្រធានបទ

  ✓ គោលការណ៍ និងនីតិវិធីឥណទាន និងបានចុះត្រួតពិនិត្យ ពង្រឹងគុណភាព អំពីប្រសិទ្ធភាពនៃការអនុវត្តការងារនៅតាមសាខានីមួយៗ។

- **ផ្នែកធនធានមនុស្ស និងរដ្ឋបាល**

  ប្រធានបទ

  ✓ គោលការណ៍ធនធានមនុស្សទាក់ទងនឹងប្រាក់សោធននិវត្តន៍ និងផ្តល់ការបណ្តុះបណ្តាលដល់និយោជិតថ្មី ដើម្បីស្វែងយល់អំពីគោលការណ៍ និងលក្ខខណ្ឌរបស់គ្រឹះស្ថាន។

- **ផ្នែកប្រតិបត្តិតាម**

  ប្រធានបទ

  ✓ គោលការណ៍ការប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការត្រួតពិនិត្យ ការពង្រឹងគុណភាពការអនុវត្តការងារជាប្រចាំ ការអនុវត្តធ្វើរបាយការណ៍នៃការដោះស្រាយបណ្តឹងអតិថិជន វិស្សលប្ល៉ូវីង របាយការណ៍សន្ទស្សន៍ថ្លៃលំដ្ឋាន និងរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ របស់សាខានីមួយៗតាមរយៈអនឡាញ។

ការបណ្តុះបណ្តាលនេះជាកត្តាមួយជួយជំរុញ និងពង្រឹងនូវសមត្ថភាពបុគ្គលិកឱ្យមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការអនុវត្តន៍ការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងសម្រេចតាមគោលដៅរបស់គ្រឹះស្ថាន។

### សកម្មភាពបុគ្គលិកចូលរួមវគ្គបណ្តុះបណ្តាលផ្ទៃក្នុង





## សកម្មភាពបុគ្គលិកពិសារអាហារ



## សកម្មភាពបញ្ចប់វគ្គ បណ្តុះបណ្តាល




## វគ្គបណ្តុះបណ្តាលខាងក្រៅ

ក្រៅពីការបណ្តុះបណ្តាលផ្ទៃក្នុង គ្រឹះស្ថានក៏បានបញ្ជូនបុគ្គលិកផ្នែក ដែលពាក់ព័ន្ធឱ្យចូលរួមការបណ្តុះបណ្តាលខាងក្រៅ និងសិក្ខាសាលាដែលបានរៀបចំឡើងដោយ ធនាគារជាតិនៃកម្ពុជា សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា)ខូ អិលធីឌី (CBC) អគ្គនាយកដ្ឋានពន្ធដារ ក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងក្រសួង និងអាជ្ញាធរដទៃទៀតដែលពាក់ព័ន្ធ។

# ដំណើរកម្សាន្តប្រចាំឆ្នាំ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី បានរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំ២០២៥ ឆ្ពោះទៅកាន់ក្រុងព្រះសីហនុ រយៈពេល០២ថ្ងៃ។ ដោយមានការចូលរួមពីបុគ្គលិកគ្រប់លំដាប់ថ្នាក់ទាំងអស់ និងមានរៀបចំកម្មវិធីជាច្រើន ដូចជា៖ ការលេងល្បែងកម្សាន្តជាក្រុម ការប្រគល់ប័ណ្ណសរសើរ ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកឆ្នើម ការចាប់រង្វាន់អនុស្សាវរីយ៍ និងការពិសារអាហារជួបជុំគ្នា។






# សកម្មភាពល្បែងកម្សាន្ត



# សកម្មភាពចាប់រង្វាន់



# អាហារសាមគ្គី



# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗ ទៅដល់គ្រួសារដែលមានប្រាក់ចំណូលទាប នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | ដុល្លារអាម៉េរិក | ពាន់រៀល |
|---|---|---|
| ខាតសម្រាប់ការិយបរិច្ឆេទ | ៦៤.៩៣២ | ២៦០.៤៤៣ |

### ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការទូទាត់ភាគលាភណាមួយសម្រាប់ការិយបរិច្ឆេទនេះទេ។

### ទុនបម្រុង និងសំវិធានធន

នៅក្នុងអំឡុងការិយបរិច្ឆេទ មានការផ្ទេរចំនួន ១៦៥.៤៥៦ដុល្លារអាម៉េរិកពីចំណេញរក្សាទុកទៅទុនបម្រុងតាមច្បាប់។

### ឥណទានពិបាកទារ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ចំណូលពេញលេញ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលឥណទានពិបាកទារ និងការធ្វើសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាបំណុលពិបាកទារទាំងអស់ត្រូវបានលុបចោល និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការលុបចោលឥណទានពិបាកទារ ឬសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលរបាយការណ៍ចំណូលពេញលេញ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយណា ដែលទំនងជាមិនអាចបង្វិលមកវិញបានក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចលក់បាននៅលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនឡើយ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំសម្រាប់ធានា បំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយកើតឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទនេះ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសង ក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនត្រូវបានវែកញែកក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបណ្តាលឱ្យមានចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានការភ័ន្តច្រឡំឡើយ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទ នេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះនៃចុងការិយបរិច្ឆេទមកទល់នឹងថ្ងៃចេញរបាយការណ៍នេះ ពុំមានកត្តាប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើង ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលរបាយការណ៍ត្រូវបានធ្វើឡើងឡើយ។

## ដើមទុន

ក្រុមហ៊ុនពុំមានការបោះផ្សាយភាគហ៊ុន នៅក្នុងការិយបរិច្ឆេទនេះទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ចុងក្រោយរួមមាន៖

លោក អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

លោក ឡុង ពិសី

លោក គង់ វ៉ាក់

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃមួយទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនដែលពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែផលប្រយោជន៍ណាមួយដែលអាចត្រូវបានគិតថាកើតឡើងដោយគុណសម្បត្តិនៃប្រតិបត្តិការទាំងនោះដូចដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ២៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារកិច្ចធ្វើការបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើង បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុវត្តគោលនយោបាយគណនេយ្យសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្នហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យបានជាប់លាប់

(ខ) អនុលោមទៅតាមគោលការណ៍ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា ("ស.រ.ហ.អ.ក.ស.ធ.ត.ម") និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាងពន្យល់ និងកំណត់បរិមាណឱ្យបានសមរម្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដែលអាចប៉ាន់ស្មានបាននិង

(ង) គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តជាសារវន្ត ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុនហើយត្រូវប្រាកដថាសេចក្តីសម្រេចចិត្ត និង/ឬ សេចក្តីណែនាំទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ៩ ដល់ ៣៩ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។

ចុះហត្ថលេខាតាងនាមក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាពហ្វាយនែន ភីអិលស៊ី
Prasethpheap Finance Plc

លោក អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី
ប្រធានក្រុមប្រឹក្សាភិបាល

លោក ឃុន ដាវុធ
អគ្គនាយក

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគហ៊ុនិករបស់
## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

### សេចក្តីរាយការណ៍លើសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ
### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា(“ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញនៅទំព័រទី៩ ដល់ ៣៩។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់មកជាមួយនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”)។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដានេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

### ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយ ស្របតាម *ក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យភាពអន្តរជាតិ)* (“ក្រមសីលធម៌ IESBA”) របស់ក្រុមប្រឹក្សាស្តង់ដាសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ ដែលពាក់ព័ន្ធទៅនឹងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ដែលមានផលប្រយោជន៍ សាធារណៈ រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើង ដោយអនុលោមតាមតម្រូវការនៃក្រមសីលធម៌ទាំងនេះ និងក្រមសីលធម៌ IESBA។

### ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មខាងលើរបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនផ្តល់នូវទម្រង់សន្និដ្ឋានជាបែបធានាណាមួយឡើយ។

ទាក់ទងជាមួយនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានកាតព្វកិច្ចក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬការយល់ដឹងរបស់យើងខ្ញុំទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាព័ត៌មានផ្សេងៗមានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍ពីការពិត តែយើងខ្ញុំមិនមានអ្វីដើម្បីរាយការណ៍ក្នុងរឿងនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលការខុសត្រូវក្នុងការវាយតម្លៃទៅលើលទ្ធភាពបន្តប្រតិបត្តិការរបស់ក្រុមហ៊ុនដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការលាតត្រដាងប្រសិនជាមាននូវកត្តាដែលពាក់ព័ន្ធនឹងនិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបអនិរន្តរភាព លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយប៉ុន្តែត្រូវតែធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យ ដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាមតិយោបល់របស់សវនកម្ម អនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជាដែលតែងតែការពារនូវកំហុសឆ្គងជាសារវន្តនៅពេលកើតមានឡើងនោះទេ។ ភាពខុសឆ្គងដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានពិចារណាថាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្តុំ អាចមាន ឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់នៅលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដែលមានជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសវនកម្ម។ យើងខ្ញុំបានធ្វើ៖

- កំណត់ និងវាយតម្លៃលើហានិភ័យកំហុសឆ្គងជាសារវន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាតើវាបណ្តាល មកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យដើម្បីជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនបានរកឃើញនូវកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ក្រុមហ៊ុននោះឡើយ។
- វាយតម្លៃនូវភាពសមស្របនៃគោលនយោបាយគណនេយ្យ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន និងកំណត់បង្ហាញដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពគណនេយ្យដែលគណៈគ្រប់គ្រងប្រើប្រាស់ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនមានច្បាស់លាស់ជាសារវន្តអាចកើតមាន ទាក់ទងទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចសង្ស័យយ៉ាងខ្លាំងលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ ប្រសិន បើយើងខ្ញុំសន្និដ្ឋានថា ភាពមិនមានច្បាស់លាស់ជាសារវន្តកើតឡើង យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុក ដាក់នៅក្នុងរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំភ្ជាប់នឹងបង្ហាញការទាក់ទងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបើការបង្ហាញ

បែបនេះ គឺមិនគ្រប់គ្រាន់ នោះមតិយោបល់របស់យើងខ្ញុំនឹងកែប្រែ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបង្កឱ្យក្រុមហ៊ុនបញ្ឈប់នូវភាពនិរន្តរភាពបាន។

- វាយតម្លៃលើបទបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមទាំងការលាតត្រដាង ថាតើរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនតំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងៗ ក្នុងរបៀបរបបមួយដែលសម្រេចបាននូវការបង្ហាញត្រឹមត្រូវ។

ក្នុងចំណោមចំណុចពាក់ព័ន្ធផ្សេងៗ យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលអំពីផែនការទំហំការងារ និងពេលវេលានៃសវនកម្ម និងចំណុចសំខាន់ៗដែលបានរកឃើញ រួមមានទាំងកង្វះខាតក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាដទៃ

របាយការណ៍នេះត្រូវបានធ្វើឡើងជូនចំពោះតែភាគហ៊ុនិករបស់ក្រុមហ៊ុនប៉ុណ្ណោះ។ យើងមិនទទួលខុសត្រូវចំពោះបុគ្គលដទៃណាម្នាក់ចំពោះខ្លឹមសារនៃរបាយការណ៍នេះទេ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនមួយផ្សេងទៀត ដែលជាគណនេយ្យករជំនាញសាធារណៈ ដែលមានរបាយការណ៍ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ បានបញ្ចេញមតិយោបល់ពិត និងត្រឹមត្រូវលើរបាយការណ៍ទាំងនោះ។

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៦

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

| | កំណត់ | ២០២៥ | | ២០២៤ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាម៉េរិក | ពាន់រៀល | ដុល្លារអាម៉េរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧ | ៥.១៥៩ | ២០.៧០៣ | ១៦.២៧៤ | ៦៥.៥០៣ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៨ | ១៤៨.៣០៧ | ៥៩៥.១៥៦ | ១៤៦.៨០៣ | ៥៩០.៨៨២ |
| សមតុល្យនៅធនាគារផ្សេងៗ | ៩ | ៣៦៣.០៦២ | ១.៤៥៦.៩៦៨ | ៨៤៩.៦៥៤ | ៣.៤១៩.៨៥៧ |
| ឥណទានទៅអតិថិជន | ១០ | ៤.៨២៣.៧២១ | ១៩.៣៥៧.៥៩២ | ៤.៩៧៩.៣៤៨ | ២០.០៤១.៨៧៦ |
| គណនីត្រូវទទួលផ្សេងៗ | ១១ | ១៩៧.៩៥៨ | ៧៩៤.៤០៥ | ១៤៤.៨២៨ | ៥៨២.៩៣៣ |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ១២ | ៣២.០៣៧ | ១២៨.៥៦៤ | ៤៦.៩២១ | ១៨៨.៨៥៧ |
| ទ្រព្យអរូបី | ១៣ | ១០.៩៨៤ | ៤៤.០៧៩ | ២១.៩៨៨ | ៨៨.៥០២ |
| ទ្រព្យសកម្មពន្ធពន្យា | ១៤ | ៧៤.១៦១ | ២៩៧.៦០៨ | ១១០.៣៣៨ | ៤៤៤.១១០ |
| **ទ្រព្យសកម្មសរុប** | | ៥.៦៥៥.៣៨៩ | ២២.៦៩៥.០៧៥ | ៦.៣១៦.១៥៤ | ២៥.៤២២.៥២០ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ឥណទានវិបារូបន៍ | ១៥ | ២១៨.៧១២ | ៨៧៧.៦៩១ | ៤៣២.២៦៣ | ១.៧៣៩.៨៥៩ |
| ប្រាក់កម្ចី | ១៦ | ២.៣៣១.២៤៣ | ៩.៣៥៥.២៧៨ | ២.៧១៩.៩៩០ | ១០.៩៤៧.៩៦០ |
| គណនីត្រូវបង់ផ្សេងៗ | ១៧ | ៤៦.៧២៧ | ១៨៧.៥១៥ | ៤០.២៦១ | ១៦២.០៥០ |
| **បំណុលសរុប** | | ២.៥៩៦.៦៨២ | ១០.៤២០.៤៨៤ | ៣.១៩២.៥១៤ | ១២.៨៤៩.៨៦៩ |
| **មូលធន** | | | | | |
| ដើមទុន | ១៨ | ២.៩១៥.៧៦៦ | ១១.៦៦៣.០៦៤ | ២.៩១៥.៧៦៦ | ១១.៦៦៣.០៦៤ |
| បុព្វលាភភាគហ៊ុន | | ៦៣.០៧៨ | ២៥៦.៩៨០ | ៦៣.០៧៨ | ២៥៦.៩៨០ |
| ដើមទុនផ្សេងៗ | ១៩ | ១៩០.០០០ | ៧៧៤.០៦០ | ១៩០.០០០ | ៧៧៤.០៦០ |
| ទុនបម្រុងតាមច្បាប់ | ២០ | ៣៦២.៦៥១ | ១.៤៦០.៣៤៧ | ១៩៧.២០៥ | ៧៩៦.៤១២ |
| ខាតបង្គរ | | (៤៧២.៧៨៨) | (១.៩១៨.៤៥០) | (២៤២.៤០៩) | (៩៩៤.១១២) |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណ | | - | ៣៨.៦៣០ | - | ៧៦.២៤៧ |
| **មូលធនសរុប** | | ៣.០៥៨.៧០៧ | ១២.២៧៤.៥៩១ | ៣.១២៣.៦៤០ | ១២.៥៧២.៦៥១ |
| **បំណុល និងមូលធនសរុប** | | ៥.៦៥៥.៣៨៩ | ២២.៦៩៥.០៧៥ | ៦.៣១៦.១៥៤ | ២៥.៤២២.៥២០ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍ចំណូលពេញលេញ

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥ ដុល្លារអាម៉េរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាម៉េរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ២១ | ៩៩៤.២១៩ | ៣.៩៨៧.៨១២ | ១.១៧២.៧០៦ | ៤.៧៧៤.០៨៦ |
| ចំណាយការប្រាក់ | ២២ | (៣៥៨.៦២១) | (១.៤៣៨.៤២៩) | (៣៥០.៨៣២) | (១.៤២៨.២៣៧) |
| ចំណូលការប្រាក់សុទ្ធ | | ៦៣៥.៥៩៨ | ២.៥៤៩.៣៨៣ | ៨២១.៨៧៤ | ៣.៣៤៥.៨៤៩ |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ១០ | (៤២.៧១២) | (១៧១.៣១៨) | (៣៥២.៥៩២) | (១.៤៣៥.៤០២) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ១០០.៩៨២ | ៤០៥.០៣៩ | ៨៦.៦៩៥ | ៣៥២.៩៣៥ |
| ចំណាយបុគ្គលិក | ២៤ | (៤៨០.៤៦៥) | (១.៩២៧.១៤៥) | (៤៩៣.៦៦៤) | (២.០០៩.៧០៦) |
| ចំណាយរំលស់ | ២៥ | (៣០.០៥៩) | (១២០.៥៦៧) | (២៥.២៥៤) | (១០២.៨០៩) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២៦ | (២១២.០៩៩) | (៨៥០.៧២៩) | (២២៨.៥៨៥) | (៩៣០.៥៦៩) |
| ខាតមុនបង់ពន្ធ | | (២៨.៧៥៥) | (១១៥.៣៣៧) | (១៩១.៥២៦) | (៧៧៩.៧០២) |
| ចំណាយពន្ធ | ២៧ | (៣៦.១៧៧) | (១៤៥.១០៦) | ២៦.៤០២ | ១០៧.៤៨៣ |
| ខាតសម្រាប់ការិយបរិច្ឆេទ | | (៦៤.៩៣២) | (២៦០.៤៤៣) | (១៦៥.១២៤) | (៦៧២.២១៩) |
| ខាតពេញលេញផ្សេងៗ សុទ្ធនៃពន្ធ | | - | (៣៧.៦១៧) | - | (១៨៩.៧៣១) |
| ខាតពេញលេញសរុបក្នុងការិយបរិច្ឆេទ | | (៦៤.៩៣២) | (២៩៨.០៦០) | (១៦៥.១២៤) | (៨៦១.៩៥០) |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍បម្រែបម្រួលមូលធន

**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥**

| | ដើមទុន | បុព្វលាភភាគហ៊ុន | ដើមទុនផ្សេងៗ | ទុនបម្រុងតាមច្បាប់ | ខាតបង្គរ | លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៦៧.៧៧០** | **៥២.១៥០** | **-** | **៣.២៨៨.៧៦៤** |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១៦៥.១២៤) | - | (១៦៥.១២៤) |
| ការបកប្រែរូបិយប័ណ្ណបរទេស | - | - | - | - | - | - | - |
| ខាតពេញលេញសរុប | - | - | - | - | (១៦៥.១២៤) | - | (១៦៥.១២៤) |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន** | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការសរុបជាមួយម្ចាស់ភាគហ៊ុន | - | - | - | ១២៩.៤៣៥ | (១២៩.៤៣៥) | - | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **១៩៧.២០៥** | **(២៤២.៤០៩)** | **-** | **៣.១២៣.៦៤០** |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (៦៤.៩៣២) | - | (៦៤.៩៣២) |
| ខាតពេញលេញសរុប | - | - | - | - | (៦៤.៩៣២) | - | (៦៤.៩៣២) |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន** | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការសរុបជាមួយម្ចាស់ភាគហ៊ុន | | | | ១៦៥.៤៤៦ | (១៦៥.៤៤៦) | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥** | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៣៦២.៦៥១** | **(៤៧២.៧៨៨)** | | **៣.០៥៨.៧០៧** |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

| | កំណត់សម្គាល់ | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនបង់ពន្ធ | | (២៨.៧៥៥) | (១១៥.៣៣៧) | (១៩១.៥២៦) | (៧៧៩.៧០២) |
| និយ័តកម្ម៖ | | | | | |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ១០ | ៤២.៧១២ | ១៧១.៣១៨ | ៣៥២.៩៩២ | ១.៤៣៥.៤០២ |
| រំលស់ទ្រព្យអរូបី | ១៣ | ១១.០០៤ | ៤៤.១៣៧ | ១២.៥១០ | ៥០.៩២៨ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ១២ | ១៩.០៥៥ | ៧៦.៤៣០ | ១២.៧៤៤ | ៥១.៨៨១ |
| ចំណូលការប្រាក់ | | (៩៩៤.២១៩) | (៣.៩៨៧.៨១២) | (១.១៧២.៧០៦) | (៤.៧៧៤.០៨៦) |
| ចំណាយការប្រាក់ | ២២ | ៣៥៨.៦២១ | ១.៤៣៨.៤២៩ | ៣៥០.៨៣២ | ១.៤២៨.២៣៧ |
| ខាតប្រតិបត្តិការមុនពេលបម្រែបម្រួលដើមទុនបង្វិល | | (៥៩១.៥៨២) | (២.៣៧២.៨៣៥) | (៦៣៥.៥៥៤) | (២.៥៨៧.៣៤០) |
| បម្រែបម្រួលដើមទុនបង្វិល | | | | | |
| ឥណទានទៅអតិថិជន | | ១១២.៩១៤ | ៤៥២.៨៩៨ | (៧៤៣.៥៨០) | (៣.០២៧.១១៤) |
| គណនីត្រូវទទួលផ្សេងៗ | | (៥៣.១៣០) | (២១៣.១០៤) | (៩.៩០៧) | (៤០.៣៣១) |
| គណនីត្រូវបង់ផ្សេងៗ | | ៦.៤៦៦ | ២៥.៩៣៥ | (១៣.៦២៣) | (៥៥.៤៦០) |
| សាច់ប្រាក់ប្រើក្នុងប្រតិបត្តិការ | | (៥២៥.៣៣២) | (២.១០៧.១០៦) | (១.៤០២.៦៦៤) | (៥.៧១០.២៤៥) |
| ការប្រាក់បានទទួល | | ៩៩៩.៩០០ | ៤.០១០.៥៩៩ | ១.២៨០.៦៣៤ | ៥.២១៣.៤៦១ |
| ពន្ធប្រាក់ចំណូលដែលបានបង់ | | - | - | (១៣.១៤៩) | (៥៣.៥៣០) |
| ការប្រាក់បានបង់ | | (៣៥៨.៦២១) | (១.៤៣៨.៤២៩) | (៣៤០.៨៨៨) | (១.៣៨៧.៧៥៥) |
| សាច់ប្រាក់សុទ្ធបានមកពី/(ប្រើក្នុង)សកម្មភាពប្រតិបត្តិការ | | ១១៥.៩៤៧ | ៤៦៥.០៦៤ | (៤៧៦.០៦៧) | (១.៩៣៨.០៦៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៤.១៧១) | (១៦.៧៣០) | (៣៦.៩៩០) | (១៥០.៥៨៦) |
| ការដាក់ប្រាក់បញ្ញើមានការកំណត់ | | - | - | (៣០០.០០០) | (១.២២១.៣០០) |
| ការដកប្រាក់បញ្ញើមានការកំណត់ | | ៥០០.០០០ | ២.០០៥.៥០០ | - | - |
| សាច់ប្រាក់សុទ្ធបានមកពី/(ប្រើក្នុង)សកម្មភាពវិនិយោគ | | ៤៩៥.៨២៩ | ១.៩៨៨.៧៧០ | (៣៣៦.៩៩០) | (១.៣៧១.៨៨៦) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ត)

| | កំណត់សម្គាល់ | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់សងប្រាក់កម្ចី | | (៣៨៨.៧៤៧) | (១.៥៥៩.២៦៤) | (៣.៤១៧.៥៩១) | (១៣.៩១៣.០១៣) |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | - | - | ៣.៧៥៤.២៩០ | ១៥.២៨៣.៧១៥ |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានមកពីសកម្មភាពហិរញ្ញប្បទាន | | (៣៨៨.៧៤៧) | (១.៥៥៩.២៦៤) | ៣៣៦.៦៩៩ | ១.៣៧០.៧០២ |
| **កំណើន/(តំហយ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ២២៣.០២៩ | ៨៩៤.៥៧០ | (៤៧៦.៣៥៨) | (១.៩៣៩.២៥៣) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ** | | (៣៨៣.០២២) | (១.៥៤១.៦៦៤) | ៩៣.៣៣៦ | ៣៨១.២៧៧ |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | | - | ៥.០៤៣ | - | ១៦.៣១២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | | (១៥៩.៩៩៣) | (៦៤២.០៥១) | (៣៨៣.០២២) | (១.៥៤១.៦៦៤) |

**សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖**

| | កំណត់សម្គាល់ | ២០២៥ ដុល្លារអាមេរិក | ២០២៥ ពាន់រៀល | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល |
|---|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៧ | ៥.១៥៩ | ២០.៧០៣ | ១៦.២៧៤ | ៦៥.៥០៣ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៨ | ២.៥១៩ | ១០.១០៩ | ១.០១៥ | ៤.០៨៥ |
| សមតុល្យនៅធនាគារផ្សេងៗ | ៩ | ៥១.០៤១ | ២០៤.៨២៨ | ៣១.៩៥២ | ១២៨.៦០៧ |
| ឥណទានវិបារូបន៍ | ១៥ | (២១៨.៧១២) | (៨៧៧.៦៩១) | (៤៣២.២៦៣) | (១.៧៣៩.៨៥៩) |
| | | (១៥៩.៩៩៣) | (៦៤២.០៥១) | (៣៨៣.០២២) | (១.៥៤១.៦៦៤) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

...ធ្វើឱ្យជីវិតអ្នកកាន់តែប្រសើរ

...Marking Life Better

Prasethpheap Finance Plc

info@prasethpheapfinance.com.kh

www.prasethpheapfinance.com.kh